**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

## កំណត់ហេតុស្តីពីការប្រជុំពិនិត្យការកែលម្អតាមអនុសាសន៍សវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត សម្រាប់ការិយបរិច្ឆេទ២០២២

ឆ្នាំពីរពាន់ម្ភៃបួន ខែមិថុនា ថ្ងៃទីម្ភៃប្រាំពីរ វេលាម៉ោងបីរសៀល ប្រតិភូសវនកម្មផ្ទៃក្នុងនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដឹកនាំដោយ លោក **យួន សុជាតិ** បានជួបប្រជុំគ្នាជាមួយថ្នាក់ដឹកនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត ដើម្បីពិភាក្សាលើលទ្ធផលនៃការកែលម្អលើការងារដែលប្រតិភូសវនករបានពិនិត្យកន្លងមក។ សមាសភាពចូលរួមមានដូចខាងក្រោម៖

**ក-សមាសភាពប្រតិភូសវនកម្មផ្ទៃក្នុង**

| | | |
|---|---|---|
| ១-លោក | **យួន សុជាតិ** | ប្រធានប្រតិភូ |
| ២-លោក | **អ៊ុង សួនរស្មី** | អនុប្រធានប្រតិភូ |
| ៣-លោក | **ហេង វាសនា** | សមាជិក |
| ៤-លោក | **ជា សីហនុធ** | សមាជិក |
| ៥-លោក | **រតន៍ អរិយ៍** | សមាជិក |
| ៦-លោក | **អេ ម៉ុនថេត** | សមាជិក |

**ខ- សមាសភាពថ្នាក់ដឹកនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត**

| | | |
|---|---|---|
| ១-លោក | **ស៊ឹម សុខជា** | អនុប្រធានមន្ទីរ |
| ២-លោក | **ផេង ភល** | ប្រធានការិយាល័យសុរិយោដី និងភូមិសាស្ត្រ |
| ៣-លោក | **ម៉ុន សុភា** | អនុប្រធានការិយាល័យសំណង់ |
| ៤-លោក | **គង់ សារ៉ា** | អនុប្រធានការិយាល័យរដ្ឋបាល |
| ៥-លោកស្រី | **អេន ធារ័ត្ន** | អនុប្រធានការិយាល័យរដ្ឋបាល |

ជាកិច្ចចាប់ផ្តើម លោក **ស៊ឹម សុខជា** អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត បានសំដែងនូវភាពសោមនស្សដល់ប្រតិភូសវនករនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចុះមកតាមដានអនុសាសន៍ដែលបានផ្តល់ឱ្យកន្លងមកដល់មន្ទីរ សម្រាប់ធ្វើការកែលម្អ និងថ្លែងអំណរ

គុណចំពោះលទ្ធផលសវនកម្មដែលសម្រេចបាន។ បន្ទាប់មក លោកអនុប្រធានមន្ទីរ បានប្រគល់នាទីជូនលោកប្រធានប្រតិភូសវនកម្មមានមតិបើកអង្គប្រជុំ÷

លោក **ឃួន សុជាតិ** ប្រធានប្រតិភូ និងជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង បានជម្រាបជូនអង្គប្រជុំថា ការចុះមកពេលនេះដោយយោងលិខិតបញ្ជាបេសកកម្មលេខ១៤៧៤ និងលេខ១៤៧៧ ដនស ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យពីការកែលម្អតាមអនុសាសន៍ បានចុះធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធដែលបានផ្តល់អនុសាសន៍ដូចខាងក្រោម÷

**ក. អនុសាសន៍របស់សវនកម្មផ្ទៃក្នុង÷**

១. មន្ទីរត្រូវពង្រឹងការងាររដ្ឋបាលលើផ្នែកចុះលេខលិខិត នៅក្នុងសៀវភៅចុះលេខលិខិតចេញ ឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។

២. មន្ទីរត្រូវរំលេចនូវទិន្នន័យលិខិតអនុញ្ញាតបើកការដ្ឋាន-បិទការដ្ឋាន និងលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់នៅក្នុងរបាយការណ៍លទ្ធផលការងាររបស់មន្ទីរ។

៣. មន្ទីរត្រូវរៀបចំជួសជុលពិតានដែលជ្រាបទឹកឱ្យបានស្អាតបាត និងបំពាក់ប្រព័ន្ធការពារអគ្គិភ័យឱ្យបានត្រឹមត្រូវ។

**ខ. វិធានការកែលម្អរបស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷**

១- មន្ទីរត្រូវជំរុញឱ្យមានការចុះហត្ថលេខាគ្រប់សមាសភាពអាជ្ញាធរគ្រប់គ្រង និងគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ លើកំណត់ហេតុស្តីពីការប្រជុំពិនិត្យ ផ្ទៀងផ្ទាត់ការរៀបចំតារាងកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២២ ឱ្យរួចរាល់ជាផ្លូវការ។

២- ឆ្នាំឃ្លាំងត្រូវធ្វើបញ្ជីវិភាគសម្រាប់កត់ត្រាតាមដានសន្និធិឃ្លាំង លើការប្រើប្រាស់សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល និងប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ស្របតាមនីតិវិធីនៃការគ្រប់គ្រងសន្និធិឃ្លាំង។

៣- លើឯកសារប្រើប្រាស់ប្រេងសម្រាប់ចុះបំពេញបេសកកម្មតាមបណ្តាក្រុង-ស្រុក មន្ទីរត្រូវមានភ្ជាប់លិខិតបេសកកម្មមកជាមួយឱ្យបានគ្រប់គ្រាន់។

បន្ទាប់មក លោកអនុប្រធានមន្ទីរ និងមន្ត្រីជំនាញពាក់ព័ន្ធមានមតិបំភ្លឺ និងបង្ហាញឯកសារដើម្បីបញ្ជាក់ពីការកែលម្អតាមអនុសាសន៍លើកឡើងខាងលើ។ ជាលទ្ធផល ប្រតិភូសវនករ និងអង្គភាពសវនដ្ឋានបានពិនិត្យព្រមទាំងឯកភាពគ្នាដូចតទៅ÷

**ក. ការឆ្លើយតបចំពោះអនុសាសន៍សវនកម្មផ្ទៃក្នុង÷**

១. មន្ទីរបានពង្រឹងការងាររដ្ឋបាលលើផ្នែកចុះលេខលិខិត នៅក្នុងសៀវភៅចុះលេខលិខិតចេញប្រចាំឆ្នាំ២០២៣ ល្អប្រសើរ។

២. មន្ទីរនឹងបញ្ចូលទិន្នន័យលិខិតអនុញ្ញាតបើកការដ្ឋាន និងលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់ នៅក្នុងរបាយការណ៍លទ្ធផលការងាររបស់មន្ទីរក្នុងពេលឆាប់ខាងមុខនេះ។

៣. មន្ទីរបាន និងកំពុងរៀបចំជួសជុលពិតានដែលជ្រាបទឹក ហើយនឹងបំពាក់ប្រព័ន្ធការពារអគ្គីភ័យក្នុងពេលឆាប់ៗ។

**ខ. ការឆ្លើយតបចំពោះវិធានការកែលម្អរបស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷**

១- មន្ទីរបានចុះហត្ថលេខាពីគ្រប់សមាសភាពអាជ្ញាធរគ្រប់គ្រង និងគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ក្នុងតារាងកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២២ រួចហើយ។

២- មន្ទីរបានធ្វើការកត់ត្រាតាមដានសន្និធិឃ្លាំង ក្នុងការប្រើប្រាស់សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល និងប្រេងឥន្ធនៈ ស្របតាមនីតិវិធីនៃការគ្រប់គ្រងសន្និធិឃ្លាំង។

៣- មន្ទីរបានភ្ជាប់លិខិតបេសកកម្មជាមួយឯកសារប្រើប្រាស់ប្រេង សម្រាប់ចុះបំពេញបេសកកម្មតាមបណ្តាក្រុង-ស្រុក រួចរាល់។

ប្រតិភូសវនករបានទទួលយកនូវមតិឆ្លើយតបរបស់សវនដ្ឋាន និងបានជម្រាបជូនសវនដ្ឋានថា ប្រតិភូសវនករនឹងត្រូវរៀបចំរបាយការណ៍ស្តីពីការកែលម្អតាមអនុសាសន៍ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត ជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ជ្រាបជារបាយការណ៍ និងមានមតិណែនាំដ៏ខ្ពង់ខ្ពស់។

ជាទីបញ្ចប់ លោកអនុប្រធានមន្ទីរ បានថ្លែងអំណរគុណចំពោះលទ្ធផលការងាររបស់ប្រតិភូ ហើយនឹងបន្តអនុវត្តការងារដែលនៅសេសសល់។

កិច្ចប្រជុំរវាងប្រតិភូសវនកម្មផ្ទៃក្នុង និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត បានបញ្ចប់សព្វគ្រប់នៅវេលាម៉ោងប្រាំ និងសាមសិបនាទីល្ងាច នាថ្ងៃខែឆ្នាំដដែលក្នុងបរិយាកាសជាភាតរៈ និងស្មារតីទទួលខុសត្រូវខ្ពស់។

**ប្រធានមន្ទីរ**
**អនុប្រធាន**

វិស្វករ.ស៊ឹម_សុខជា

**ប្រធានប្រតិភូ**

យួន_សុជាតិ

# ឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធទី ១ - ការអនុវត្តអនុសាសន៍សវនកម្មគ្រាមុន

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** **សវនដ្ឋាន : មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត**

របាយការណ៍សវនកម្មៈលេខ០៧២ របក/ សផក កាលបរិច្ឆេទបញ្ចប់របាយការណ៍ស្ថាពរៈចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣

*អាទិភាព (ប្រសិនមាន)

- ខ្ពស់: ដើម្បីកាត់បន្ថយហានិភ័យសំខាន់ៗដែលនាំឱ្យខូចខាតងាយរងគ្រោះ ឬបាត់បង់កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន។
- មធ្យម: ដើម្បីចាត់វិធានការលើបញ្ហាដែលមិនទាន់មានលក្ខណៈល្អប្រសើរ និងដែលសំខាន់សម្រាប់ពង្រឹងប្រព័ន្ធ និងនីតិវិធី។
- ទាប: ពង្រឹងការត្រួតពិនិត្យដែលមានស្រាប់ ឬចងក្រងឯកសារក្នុងទីកន្លែងដែលមិនសូវសំខាន់។

*វិធានការដែលត្រូវអនុវត្តដោយថ្នាក់ដឹកនាំ

*អព: បានអនុវត្តតាមអនុសាសន៍ពេញលេញ និងបានកាត់បន្ថយនូវហានិភ័យឱ្យដល់កម្រិតមួយអាចទទួលយកបាន។

*អខ: បានអនុវត្តតាមអនុសាសន៍ខ្លះ និងហានិភ័យសំណល់ស្ថិតក្នុងកម្រិតមួយមិនអាចទទួលយកបាន។

*មអ: មិនបានអនុវត្តតាមអនុសាសន៍ និងហានិភ័យនៅតែមាន។

*មព: មិនមានហានិភ័យពាក់ព័ន្ធ និងមិនមានហានិភ័យសំណល់ទៀតទេ។

| លេខអនុសាសន៍ | អនុសាសន៍សវនកម្ម | *អាទិភាព (សូមមើល ខ្ពស់/ មធ្យម/ ទាប) | មន្ត្រីទទួលបន្ទុក | កាលបរិច្ឆេទឯកភាពអនុវត្ត | កាលបរិច្ឆេទតាមដាន | វិធានការដោយថ្នាក់ដឹកនាំ (សូមមើល ខាងលើ) | ភស្តុតាងនៃការអនុវត្តដោយថ្នាក់ដឹកនាំ ឬកាលបរិច្ឆេទត្រូវកែសម្រួល និងឯកភាពជាមួយថ្នាក់ដឹកនាំសម្រាប់ការអនុវត្តបន្ត។ |
|---|---|---|---|---|---|---|---|
| ១ | មន្ទីរត្រូវពង្រឹងការងាររដ្ឋបាលលើផ្នែកចុះលេខលិខិតនៅក្នុងសៀវភៅចុះលេខលិខិតចេញ ឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។ | មធ្យម | ប្រធានមន្ទីរ | | | អ.ព | បានកែលម្អ |
| ២ | មន្ទីរត្រូវរំលេចនូវទិន្នន័យលិខិតអនុញ្ញាតបើកការដ្ឋាន បិទការដ្ឋាន និងលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់នៅក្នុងរបាយការណ៍លទ្ធផលការងាររបស់មន្ទីរ។ | មធ្យម | ប្រធានមន្ទីរ | | | អ.ព | បាន និងកំពុងអនុវត្ត |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | មន្ទីរត្រូវរៀបចំជួសជុលពិតានដែលជ្រាបទឹកឱ្យបានស្អាតបាត និងបំពាក់ប្រព័ន្ធការពារអគ្គីភ័យ ឱ្យបានត្រឹមត្រូវ។ | មធ្យម | ប្រធានមន្ទីរ | | | អ.៣ | បាន និងកំពុងអនុវត្ត |

រៀបចំដោយៈ លោក **រតន៍ អរិយ៍**　　កាលបរិច្ឆេទៈ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤

ត្រួតពិនិត្យដោយៈ លោក **ហេង វាសនា**　　កាលបរិច្ឆេទៈ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤

ខេត្តកំពត, ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤

**ប្រធានមន្ទីរ**

អនុប្រធាន

វិស្វករ.ស៊ឹម_សុខជា

## ២. ឧបសម្ព័ន្ធទី ២ - ផែនការសកម្មភាពកែលម្អ

របាយការណ៍ : សវនកម្មនៅ **មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត ការិយបរិច្ឆេទ២០២២**

របាយការណ៍លេខ: ០៧២ /របក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២៣

- ខ្ពស់: ដើម្បីកាត់បន្ថយហានិភ័យសំខាន់ៗដែលនាំឱ្យខូចខាត ងាយរងគ្រោះ ឬបាត់បង់កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន។
- មធ្យម: ដើម្បីចាត់វិធានការលើបញ្ហាដែលមិនទាន់មានលក្ខណៈល្អប្រសើរ និងដែលសំខាន់ពង្រឹងប្រព័ន្ធ និងនីតិវិធី
- ទាប: ពង្រឹងការត្រួតពិនិត្យដែលមានស្រាប់ឬចងក្រងឯកសារក្នុងទីដែល មិនសូវសំខាន់
- អ.ព: អនុវត្តតាមអនុសាសន៍ឱ្យបានពេញលេញ និងកាត់បន្ថយនូវហានិភ័យឱ្យដល់កម្រិតមួយអាចទទួលយកបាន ។

| អនុសាសន៍លេខ | សកម្មភាពដែលថ្នាក់ដឹកនាំបានឯកភាព | អាទិភាព* | មន្ត្រីទទួលបន្ទុក | កាលបរិច្ឆេទឯកភាពបញ្ចប់ការអនុវត្ត |
|---|---|---|---|---|
| **១.ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ** | | | | |
| **ក.** មន្ទីរត្រូវពង្រឹងការងាររដ្ឋបាលលើផ្នែកចុះលេខលិខិត នៅក្នុងសៀវភៅចុះលេខលិខិតចេញ ឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។ | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរនឹងធ្វើការកែលម្អ ក្នុងការចុះលេខនៅក្នុងសៀវភៅចុះលេខលិខិតចេញ ឱ្យបានល្អប្រសើរឡើងវិញ។ |
| **ខ.** មន្ទីរត្រូវរំលេចនូវទិន្នន័យលិខិតអនុញ្ញាតបើកការដ្ឋាន-បិទការដ្ឋាន និងលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់នៅក្នុងរបាយការណ៍លទ្ធផលការងាររបស់មន្ទីរ។ | អ.ព | ខ្ពស់ | ប្រធានមន្ទីរ | មន្ទីរនឹងរំលេចនូវទិន្នន័យលិខិតអនុញ្ញាតបើកការដ្ឋាន-បិទការដ្ឋាន និងលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់នៅក្នុងរបាយការណ៍លទ្ធផលការងាររបស់មន្ទីរ។ |

| | | | | |
|---|---|---|---|---|
| **គ.** មន្ទីរត្រូវរៀបចំជួសជុលពិតានដែលជ្រាបទឹកឱ្យបានស្អាតបាត និងបំពាក់ប្រព័ន្ធការពារអគ្គីភ័យឱ្យបានត្រឹមត្រូវ។ | អ.៣ | ខ្ពស់ | ប្រធានមន្ទីរ | មន្ទីរនឹងធ្វើការជួសជុលពិតានដែលជ្រាបទឹក និងបំពាក់ប្រព័ន្ធការពារអគ្គីភ័យ នៅក្នុងបន្ទប់ដាក់ម៉ាស៊ីនមេ (Server) ជាបន្ទាន់។ |

**ប្រធានមន្ទីរ**

បណ្ឌិត ជាញ់_សារី

**ប្រតិភូសវនករ**

យួន_សុជាតិ